**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១២៦ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៣១៥ /០០៣ ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ អក្សរកាត់ គ.ស.អ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ដែលមានសមាសភាព ដូចខាងក្រោម ៖

១. សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២. ឯកឧត្ដម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អនុប្រធាន

៣. ឯកឧត្ដម **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤. ឯកឧត្ដម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៥. ឯកឧត្ដម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សមាជិក

៦. ឯកឧត្ដម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក

៧. ឯកឧត្ដម **សុខ ចិន្ដា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៨. ឯកឧត្ដម **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៩. ឯកឧត្ដម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១០.ឯកឧត្ដមនាយឧត្ដមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក

១១.ឯកឧត្ដមនាយឧត្ដមសេនីយ៍ **ប៉ុល សារឿន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

១២.ឯកឧត្ដមនាយឧត្ដមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៣.ឯកឧត្ដមនាយឧត្ដមសេនីយ៍ **ម៉ៅ ច័ន្ទណារិន** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្ដុភារ និង ហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ សមាជិក

១៤.អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត សមាជិក

**មាត្រា ២** : គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍មានភារកិច្ច ដូចតទៅ ៖

- តាមដាន ត្រួតពិនិត្យ និងគ្រប់គ្រងការប្រើប្រាស់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ធានាឲ្យដំណើរការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ តាមនីតិកាល និងអាណត្តិនីមួយៗ ប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព គ្មានការភ័យខ្លាច ការបំភិតបំភ័យ ការគម្រាមកំហែង និងគ្មានអំពើហិង្សាផ្សេងៗ ។
- ធ្វើការពិគ្រោះយោបល់ និងចាត់ចែងផ្ដល់កិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ រួមទាំងវិស័យការងារផ្សេងៗទៀតតាមសំណើរបស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ពិសេសច្បាប់

ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ផែនការអន្តរស្ថាប័នរបស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប ក្រមសីលធម៌ និងសេចក្តីណែនាំផ្សេងៗទៀត ដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

- ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងអប់រំផ្សព្វផ្សាយគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់គ្រប់យន្តការ រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោត និងភ្នាក់ងារសន្តិសុខបោះឆ្នោតឲ្យបានជ្រួតជ្រាប និងដើម្បីសហការអនុវត្តធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការបោះឆ្នោតឲ្យមានលក្ខណៈកាន់តែប្រសើរឡើង ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។
- ចាត់ចែងគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស សម្ភារ ឧបករណ៍បច្ចេកទេស និងមធ្យោបាយគ្រប់ប្រភេទរបស់ក្រសួង /ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដែលមានស្រាប់ ក្នុងទិសដៅជម្រុញយុទ្ធនាការការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតឲ្យទទួលបានជោគជ័យ ។
- លើកគម្រោងស្នើថវិកាបំប៉នដល់គ្រប់យន្តការ រចនាសម្ព័ន្ធ និងភ្នាក់ងារសន្តិសុខបោះឆ្នោត និងគម្រោងថវិកាសម្រាប់ការផ្គត់ផ្គង់ជាសម្ភារ មធ្យោបាយប្រើប្រាស់ ប្រេងឥន្ធនៈ និងការចំណាយចាំបាច់ផ្សេងៗទៀតបម្រើដល់កិច្ចប្រតិបត្តិការការពារយុទ្ធនាការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតនីមួយៗដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងអនុម័ត ។
- ត្រូវធ្វើរបាយការណ៍ជាប្រចាំ ជុំវិញស្ថានការណ៍សន្តិសុខបោះឆ្នោត និងអំពីសកម្មភាពប្រតិបត្តិការរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោតជូនរាជរដ្ឋាភិបាលជ្រាប ។ ក្នុងករណីចាំបាច់ត្រូវរាយការណ៍បន្ទាន់
បំពេញភារកិច្ចផ្សេងៗតាមបញ្ញត្តិច្បាប់ជាធរមាន និងតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។
- ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងមានវិធានការដោះស្រាយឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ។

**មាត្រា ៣ :** គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។

គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ត្រូវមានលេខាធិការដ្ឋានមួយ ជាសេនាធិការ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលសមាសភាព និងតួនាទីភារកិច្ចរបស់លេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ។

**មាត្រា ៤ :** គណៈអភិបាលរាជធានី ខេត្ត និងជាគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តដែលមានស្រាប់ ត្រូវបានកំណត់ជាស្វ័យប្រវត្តិជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រងដឹកនាំបញ្ជា និងត្រួតពិនិត្យទៅលើការអនុវត្តរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តរៀងៗខ្លួន ។ កម្លាំងនគរបាល ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទដែលមានមូលដ្ឋានឈរជើងនៅក្នុងទឹកដីភូមិសាស្ត្ររាជធានី ខេត្តនីមួយៗ ត្រូវរៀបចំឲ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ផ្អែកតាមផែនការដែលបានកំណត់ ។

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន

និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គស្នងការនគរបាលជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**<u>កន្លែងទទួល</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ